# ប្រកាសលេខ

# ២៦៧

# ស្ដីពីការឈប់

# សំរាកពិសេស

www.ekasar.com

00077

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ : ២៦៧ សកបយ.

ភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១

# ប្រកាស
# ស្តីពី
# ការឈប់សំរាកពិសេស

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

<u>ប្រការ១</u>.- និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ មានសិទ្ធិអនុញ្ញាតអោយកម្មករនិយោជិតខ្លួនបានឈប់សំរាកពិសេសដោយមានប្រាក់ឈ្នួល ដែលមានថិរវេលាមិនលើសពីប្រាំពីរថ្ងៃក្នុងមួយឆ្នាំ ក្នុងឱកាសដែលកម្មករនិយោជិតមានធុរៈផ្ទាល់ខ្លួន ឬក្នុងឱកាសមានព្រឹត្តិការណ៍ប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិតនោះ ដូចជា :-

www.ekasar.com



-ការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន

-ប្រពន្ធសំរាលកូន

-រៀបអាពាហ៍ពិពាហ៍កូន

-ប្ដី ប្រពន្ធ កូន ឪពុក ម្ដាយមានជម្ងឺ ឬទទួលមរណភាព ។

ប្រការ២.- និយោជកអាចធ្វើការកាត់កងការឈប់សំរាកពិសេសនេះ ពីការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិត បើកម្មករនិយោជិកនោះមិនទាន់អនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនទេ ឬអាចតំរូវអោយកម្មករនិយោជិតធ្វើការសងវិញ បើកម្មករនិយោជិតនោះបានអនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនហើយ ។

ប្រការ៣.- ការធ្វើការសងអាចអនុវត្តបានតែក្នុងរយះពេល ៩០ ថ្ងៃក្រោយថ្ងៃឈប់សំរាកពិសេស ។ ការធ្វើការសងត្រូវអនុវត្តក្នុងថ្ងៃធ្វើការធម្មតា និងក្នុងល័ក្ខខ័ណ្ឌដែលថិរវេលាធ្វើការសរុបមិនលើសពី ១០ ម៉ោង ក្នុងមួយថ្ងៃ ឬលើសពី ៥៤ ម៉ោង ក្នុងមួយសប្ដាហ៍ ។

ប្រការ៤.- ការធ្វើការសងត្រូវអោយឈ្នួលតាមអត្រាពេលម៉ោងធ្វើការធម្មតា ។

ប្រការ៥.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៧៦ សកអ.ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៦.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងប្រកាសព័ត៌មាន

"ដើម្បីផ្សព្វផ្សាយ"

-អគ្គនាយកដ្ឋាន ការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

-មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក

-សហព័ន្ធសហជីព

"ដើម្បីអនុវត្ត"

-ក្រុមបណ្ដាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"

-រាជកិច្ច

-កាលប្បវត្តិ និងឯកសារ